- បានឃើញអនុក្រឹត្យលេខ ៥៦ អនក្រ.តត ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- យោងតាមស្មារតីនៃអង្គប្រជុំក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា លើកទី ៤ កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩

## ស ម្រេ ច

**ប្រការ ១.** រៀបចំរចនាសម្ព័ន្ធ និង កំណត់មុខងារនិងភារកិច្ចរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ហៅកាត់ថា "**ស.ហ.ក**" និង ការិយាល័យ និង ផ្នែកក្រោមឱវាទនៅក្នុងប្រការបន្តបន្ទាប់ខាងក្រោម ។

**ប្រការ ២.-** ស.ហ.ក មានមុខងារ និង ភារកិច្ចចំបង១គឺ ÷

ក- ទទួលរបាយការណ៍ប្រតិបត្តិការសង្ស័យ ប្រតិបត្តិការសាច់ប្រាក់ និងព័ត៌មានស្តីពីការសង្ស័យនៃការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

ខ- ប្រមូលព័ត៌មានដែល ស.ហ.ក យល់ថាទាក់ទងនឹងសកម្មភាពរបស់ខ្លួន ស្តីពីការសម្អាតប្រាក់ ឬហិរញ្ញប្បទានភេរវកម្ម ហើយដែលមានផ្សព្វផ្សាយជាសាធារណៈ រួមមាន ទិន្នន័យពាណិជ្ជកម្ម ក៏ដូចជាព័ត៌មានផ្សេង១ ទៀតដែលចាំបាច់សម្រាប់អនុវត្តមុខងាររបស់ខ្លួន ដូចជា ព័ត៌មានដែលបានប្រមូល និងរក្សាទុកក្នុងទិន្នន័យដោយបុគ្គលរាយការណ៍

គ- យកតាមកាលានុវត្តស្របតាមច្បាប់នូវព័ត៌មានហិរញ្ញវត្ថុ រដ្ឋបាល និង ព័ត៌មានសម្រាប់ការពង្រឹងការអនុវត្តន៍ច្បាប់ ដែលចាំបាច់សម្រាប់ការបំពេញមុខងាររបស់ខ្លួន រួមទាំងព័ត៌មានដែលត្រូវបានប្រមូល និង ថែរក្សាទុកក្នុងទិន្នន័យរបស់ស្ថាប័នសាធារណៈផ្សេង១

ឃ- វិភាគ និង វាយតម្លៃនូវរាល់របាយការណ៍ប្រតិបត្តិការសង្ស័យនិងព័ត៌មានពាក់ព័ន្ធ ដើម្បីកំណត់ពីមូលដ្ឋានសមស្របដែលនាំឱ្យជឿជាក់ថាបទល្មើសសម្អាតប្រាក់ ឬបទល្មើសហិរញ្ញប្បទានភេរវកម្ម បានកើតឡើង ហើយក្នុងករណីនេះ បញ្ជូនសំណុំរឿងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីស៊ើបអង្កេតពីបទល្មើស

ង- ចងក្រងស្ថិតិ និងកត់ត្រាអំពីរបាយការណ៍ប្រតិបត្តិការសង្ស័យនិងសាច់ប្រាក់ ដែលបានទទួល វិភាគ និងបញ្ជូនទៅស្ថាប័នមានសមត្ថកិច្ច និងផ្តល់ព័ត៌មានទាំងនោះទៅស្ថាប័នសាធារណៈផ្សេងទៀត យោងតាមរឿងហេតុដែលពាក់ព័ន្ធ

ច- ផ្តល់មតិទៅបុគ្គលរាយការណ៍ និង ស្ថាប័នពាក់ព័ន្ធផ្សេង១ នូវលទ្ធផលនៃរបាយការណ៍ប្រតិបត្តិការសង្ស័យ ឬព័ត៌មានផ្សេង១ ដូចមានចែងនៅក្នុងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

ឆ- ធានាថា រាល់ព័ត៌មានផ្ទាល់ខ្លួនដែលស្ថិតនៅក្នុងដៃរបស់ខ្លួន ត្រូវបានការពារមិនឱ្យបើកចំហដោយគ្មានការអនុញ្ញាត

ជ- ចាត់វិធានការ ដើម្បីលើកកម្ពស់ការយល់ដឹងរបស់សាធារណជន អំពីការងារទាក់ទងដល់ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

**ប្រការ ៣.-** ស.ហ.ក មានការិយាល័យចំនួន ៤ នៅក្រោមឱវាទ ហើយការិយាល័យទាំងនោះមានកម្រិតស្មើនឹងការិយាល័យនានានៅធនាគារជាតិនៃកម្ពុជា ។

១- ការិយាល័យច្បាប់ រដ្ឋបាល និង ព័ត៌មានវិទ្យា

២- ការិយាល័យវិភាគរបាយការណ៍

៣-ការិយាល័យតាមដានការប្រតិបត្តិ

៤- ការិយាល័យសហប្រតិបត្តិការ

ការិយាល័យ និង ផ្នែកនីមួយៗនៅក្រោមចំណុះ ត្រូវដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយឬច្រើនរូប ជួយធ្វើការតាមការចាំបាច់ ។

**ប្រការ ៤.** ការិយាល័យច្បាប់ រដ្ឋបាល និងព័ត៌មានវិទ្យា មានមុខងារនិងភារកិច្ចជួយ ស.ហ.គ សម្របសម្រួល និងតាក់តែងលិខិតបទដ្ឋានគតិយុត្ត ការងាររដ្ឋបាលទូទៅ និងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា។ ការិយាល័យនេះរួមមាន ៣ ផ្នែក ដែលមានភារកិច្ចដូចតទៅ÷

១. ផ្នែកច្បាប់

- សហប្រតិបត្តិការជាមួយបញ្ញត្តិករ និង អាជ្ញាធរអាណាព្យាបាលបុគ្គលរាយការណ៍ ក្នុងការចេញផ្សាយសេចក្តីណែនាំរួមគ្នាអំពីកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- ពិនិត្យឡើងវិញនូវសេចក្តីណែនាំដែលបានចេញផ្សាយ និងណែនាំបុគ្គលរាយការណ៍ពីរបៀបអនុវត្ត
- ផ្តល់ការប្រឹក្សាផ្លូវច្បាប់ និងបទប្បញ្ញត្តិ
- ពិនិត្យឡើងវិញពីគោលនយោបាយ និងសំណើដាក់ទណ្ឌកម្ម
- ណែនាំពីការរៀបចំសេចក្តីព្រាងកិច្ចព្រមព្រៀងក្នុងស្រុក និងអន្តរជាតិ
- តាក់តែងលិខិតបទដ្ឋានគតិយុត្ត

២. ផ្នែកព័ត៌មានវិទ្យា

- ស្វ័យប្រវត្តិកម្មការិយាល័យ (Office Automation)
- គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យារបស់ ស.ហ.គ
- ដោះស្រាយរាល់បញ្ហាដែលកើតឡើងនៅក្នុងប្រព័ន្ធព័ត៌មានវិទ្យា
- ការពារប្រព័ន្ធឱ្យដំណើរការប្រក្រតី សុវត្ថិភាព និងទប់ស្កាត់មិនឱ្យអ្នកផ្សេងជ្រៀតចូលយកព័ត៌មានក្នុងប្រព័ន្ធព័ត៌មានវិទ្យា
- គ្រប់គ្រងសំណុំរឿងជាក់ស្តែងតាមប្រព័ន្ធព័ត៌មានវិទ្យា (Electronic Case Management)

៣. ផ្នែករដ្ឋបាល

- ទទួល បញ្ជូនតាមមុខសញ្ញា និងរក្សាទុកនូវរាល់លិខិត ឬឯកសារដែលបានផ្ញើចូល
- ផ្គត់ផ្គង់សម្ភារៈ-មធ្យោបាយបម្រើការងារតាមសេចក្តីត្រូវការជាក់ស្តែង
- សហការ និងសម្របសម្រួលក្នុងការរៀបចំរបាយការណ៍ជូនក្រុមប្រឹក្សាភិបាល
- គ្រប់គ្រងបញ្ជីវត្តមានមន្ត្រីបុគ្គលិក
- រៀបចំកម្មវិធីការងារសម្រាប់ថ្នាក់ដឹកនាំ និងធានាពិធីការចំពោះភ្ញៀវនិងពិធីផ្សេងៗ
- ចូលរួមកសាងគម្រោងថវិកាប្រចាំត្រីមាសសម្រាប់ទ្រទ្រង់ដំណើរការអង្គភាពទាំងមូល
- រៀបចំរបាយការណ៍ប្រចាំគ្រារបស់ ស.ហ.គ
- ការគ្រប់គ្រងបញ្ជីបុគ្គលរាយការណ៍

- ការរក្សាសុវត្ថិភាពរបស់ ស.ហ.ក ។

**ប្រការ ៥.** ការិយាល័យវិភាគរបាយការណ៍ មានមុខងារ និងភារកិច្ចទទួលរបាយការណ៍ប្រតិបត្តិការសង្ស័យ និងព័ត៌មានសង្ស័យផ្សេងៗ យកមកវិភាគ និងបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ច ។ ការិយាល័យនេះមាន ២ ផ្នែក ដែលមានភារកិច្ចដូចតទៅ ÷

១. ផ្នែកទទួល និងវិភាគ

- ប្រមូល និងទទួលរបាយការណ៍ប្រតិបត្តិការសង្ស័យ ប្រតិបត្តិការសាច់ប្រាក់ និងព័ត៌មានផ្សេងទៀត
- ទទួលរបាយការណ៍អេឡិចត្រូនិកពីបុគ្គលរាយការណ៍
- ស្វែងរកព័ត៌មានបន្ថែម និងវិភាគរបាយការណ៍ប្រតិបត្តិការសង្ស័យ និងរបាយការណ៍ប្រតិបត្តិការសាច់ប្រាក់
- បញ្ចូល រក្សាទុក និង ដំណើរការទិន្នន័យក្នុងប្រព័ន្ធព័ត៌មានវិទ្យា
- ទំនាក់ទំនងជាមួយបុគ្គលរាយការណ៍

២. ផ្នែកបញ្ជូន និងទទួលយោបល់

- រៀបចំរបាយការណ៍ប្រតិបត្តិការសង្ស័យ និងរបាយការណ៍ព័ត៌មានហិរញ្ញវត្ថុ
- បញ្ជូនព័ត៌មានសង្ស័យទៅអាជ្ញាធរមានសមត្ថកិច្ច
- បញ្ជូន និង ទទួលយោបល់ពីអាជ្ញាធរមានសមត្ថកិច្ច ។

**ប្រការ ៦.** ការិយាល័យតាមដានការប្រតិបត្តិ មានមុខងារ និងភារកិច្ច ត្រួតពិនិត្យ និងតាមដានការប្រតិបត្តិតាមកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍ និងបណ្តុះបណ្តាល និងបង្កើនការយល់ដឹងរបស់បុគ្គលរាយការណ៍ និងសាធារណជន ។ ការិយាល័យនេះមាន ២ ផ្នែក ដែលមានភារកិច្ចដូចតទៅ ÷

១. ផ្នែកតាមដានការប្រតិបត្តិ

- ត្រួតពិនិត្យ និងតាមដានការប្រតិបត្តិតាមកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍
- រៀបចំសេចក្តីព្រាង និងចេញផ្សាយទម្រង់របាយការណ៍
- សម្គាល់អត្តសញ្ញាណគ្រប់បុគ្គលរាយការណ៍ ដើម្បីឱ្យអនុវត្តកាតព្វកិច្ចរាយការណ៍
- ពង្រឹងការអនុវត្ត និងការប្រតិបត្តិតាមគោលនយោបាយនិងយុទ្ធសាស្ត្រ
- សហការ និងសម្របសម្រួលជាមួយអាជ្ញាធរអាណាព្យាបាលរបស់បុគ្គលរាយការណ៍ ដើម្បីត្រួតពិនិត្យការប្រតិបត្តិតាមកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

- ផ្តល់អនុសាសន៍ឱ្យអាជ្ញាធរអាណាព្យាបាលរបស់បុគ្គលរាយការណ៍មានវិធានការពង្រឹងការអនុវត្ត និងលើកសំណើដាក់ទណ្ឌកម្ម បើចាំបាច់

២. ផ្នែកបណ្តុះបណ្តាល និងបង្កើនការយល់ដឹង

- បណ្តុះបណ្តាល និង បង្កើនការយល់ដឹងពីកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- រៀបចំផែនការ និងកម្មវិធីបណ្តុះបណ្តាលនិងបង្កើនការយល់ដឹងដល់បុគ្គលរាយការណ៍និងសាធារណជន
- សហការជាមួយការិយាល័យពាក់ព័ន្ធផ្សេងៗ ដើម្បីបង្ហាញពីករណីជាក់ស្តែងទាក់ទងនឹងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- សហការ និងសម្របសម្រួលជាមួយអាជ្ញាធរអាណាព្យាបាលបុគ្គលរាយការណ៍លើការងារបណ្តុះបណ្តាល និងបង្កើនការយល់ដឹង ។

**ប្រការ ៧.** ការិយាល័យសហប្រតិបត្តិការ មានមុខងារ និងភារកិច្ចសហប្រតិបត្តិការ និងសម្របសម្រួលជាមួយស្ថាប័នក្នុងស្រុក និងដៃគូអន្តរជាតិ សិក្សាស្រាវជ្រាវ និងវិភាគករណីជាក់ស្តែង នៃការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។ ការិយាល័យនេះរួមមាន ២ ផ្នែក ដែលមានភារកិច្ច ដូចតទៅ ÷

១. ផ្នែកសហប្រតិបត្តិការក្នុងប្រទេស

- រៀបចំអនុស្សរណៈយោគយល់គ្នាជាមួយស្ថាប័នពាក់ព័ន្ធក្នុងប្រទេស
- បញ្ជូនសំណួរទាក់ទងនឹងការអនុវត្តកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មទៅស្ថាប័នពាក់ព័ន្ធក្នុងប្រទេស
- ផ្តល់យោបល់ទាក់ទងនឹងការអនុវត្តកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- រៀបចំការប្រជុំ និង ដោះស្រាយរាល់ការលំបាកដែលអាចកើតមាន
- ប្រមូល និង រក្សាទុក ករណីជាក់ស្តែងនៃការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មក្នុងប្រទេសយកមកសិក្សា និងផ្សព្វផ្សាយ ។

២. ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- រៀបចំរបាយការណ៍សម្រាប់ការប្រជុំក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ និងការប្រជុំផ្សេងៗ
- សហប្រតិបត្តិការជាមួយដៃគូអន្តរជាតិក្នុងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- រៀបចំអនុស្សរណៈយោគយល់គ្នាស្តីពីការដោះដូរព័ត៌មាន និងកិច្ចសហប្រតិបត្តិការអន្តរជាតិ
- សហការជាមួយដៃគូអន្តរជាតិក្នុងការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- ប្រមូល និងរក្សាទុកករណីជាក់ស្តែងនៃការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មអន្តរជាតិយកមកសិក្សានិងផ្សព្វផ្សាយ

- រៀបចំឯកសារដើម្បីចូលជាសមាជិកអង្គការអន្តរជាតិនានា ក្នុងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

**ប្រការ ៨.-** ក្រៅពីភារកិច្ចដូចមានចែងក្នុងប្រការខាងលើ ការិយាល័យនីមួយៗត្រូវអនុវត្តភារកិច្ចផ្សេងទៀត ដែលអគ្គលេខាធិការ ស.ហ.ក ប្រគល់ជូន ។

**ប្រការ ៩.-** អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ១០.-** ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ ២០០៩

**ទេសាភិបាល**

**និងជាប្រធានក្រុមប្រឹក្សាគ្រប់គ្រងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**

**ជា ចាន់តូ**

កន្លែងទទួល៖

- ដូចមាត្រា ៩ "ដើម្បីអនុវត្ត"
- ឯកសារ
- កាលប្បវត្តិ

ចម្លងជូន៖

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

Unofficial Translation

**Prakas**
**on**
**Structures Duties and Functions of the Cambodia Financial Intelligence Unit**

**The Governor of the National Bank of Cambodia**

- With reference to the Constitution of the Kingdom of Cambodia,
- With reference to Royal Kram N° NS/RKM/0196/27 of January 26, 1996, promulgating the Law on the Organization and Conduct of the National Bank of Cambodia,
- With reference to Royal Kram N° NS/RKM/1206/036 of December 29, 2006, promulgating amendment article 14 and 57 of law on the Organization and Conduct of the National Bank of Cambodia,
- With reference to Royal Kram N° NS/RKM/1199/13 of November 18, 1999 promulgating law on the Banking and Financial Institutions,
- With reference to Royal Kram N° NS/RKM/0607/014 of June 24, 2007, promulgating the Law on Anti-Money Laundering and Combating the Financing of Terrorism,
- With reference to the Royal Decree NS/RKT/0508/526 of May 13, 2008, on the appointment of H.E. Chea Chanto, Governor of the National Bank of Cambodia,
- With reference to the Sub-Decree N° 10 ANKR.BK of January 29, 2008, on the establishment of Cambodia Financial Intelligence Unit,
- With reference to the Sub-Decree N° 96 ANKR.TT of February 04, 2008, on the appointment of the Cambodia Financial Intelligence Unit's Board of Director
- With reference to the 4th meeting of the Cambodia Financial Intelligence Unit's Board of Director on September 15, 2009.

**Decides**

**Article 1.-** To create structure and set out duties and functions of Cambodia Financial Intelligence Unit, hereinafter called "CAFIU"; and its divisions and sections in the following articles.

**Article 2.-** The CAFIU has the following major duties and functions:

a) To receive suspicious and cash transaction reports and information suspected of money laundering or terrorism financing;

b) To collect information that the CAFIU considers relevant to money laundering or terrorism financing activities which are publicly available, including

commercially available databases, as well as other information necessary to carry out its functions, such as information collected maintained and stored in the database by the reporting entities;

c) To have access on a timely basis to financial, administrative and law enforcement information that is necessary to undertake its functions set forth by this Article, including information collected and maintained by, or stored in the databases of, any public entities;

d) To analyze and assess all suspicious transaction reports and related information in order to determine whether there are reasonable grounds to believe that a money laundering offense or a terrorism financing offense has been committed and in such cases refer the matter to the relevant law enforcement authority for criminal investigation;

e) To compile statistics and records on suspicious and cash transaction reports received, analyzed and forwarded to the law enforcement authorities and disseminate information to other public agencies on related matters as required;

f) To provide feedback to reporting entities and other relevant agencies regarding the outcome of suspicious transaction reports or information provided to it under the Law on Anti-Money Laundering and Combating Financing of Terrorism;

g) To ensure that personal information under its control is protected from unauthorized disclosure;

h) To enhance public awareness and understanding of matters related to money laundering and terrorism financing.

**Article 3.-** The CAFIU shall have four divisions under its control and those whose level is equal to that of other divisions of the National Bank of Cambodia.

1- Legal Administrative and Information Technology Division

2- Transaction Report Analysis Division

3- Compliance Monitoring Division

4- Co-operation Division

Divisions and sections shall be lead by a head with the support from one or several deputy head as necessary.

**Article 4.-** Legal Administrative and Information Technology Division shall help the CAFIU to facilitate and compose legal instruments, general administrative affairs, and information technology management. This division shall have three sections with the following functions:

1- Legal Section

- Co-operate with regulatory and supervisory authorities of reporting entities in issuing joint guidelines on Anti-Money Laundering and combating the Financing of Terrorism (AML/CFT) obligations
- Review any issued guidelines and direct reporting entities on how to implement them
- Provide legal and regulatory advise
- Review the policy and request for sanctions
- Guide on how to draft domestic and international
- Compose legal instruments

2- Information Technology Section

- Office Automation
- Information Management of the CAFIU
- Resolve any problems caused in the information technology
- Protect the system to work regularly with safety and prevent it from any spy and access
- Electronic Case Management

3- Administrative Section

- Receive, disseminate and maintain any incoming letters or documents
- Provide office materials as needed
- Co-operate and facilitate the reports to the Board of Director
- Manage the attendance list of staff
- Prepare work schedule for management level and ensure appropriate protocols for guests and any events
- Participate in establishing periodic budget to sustain the unit
- Prepare periodic report of the CAFIU
- Maintain reporting entity list
- Maintain security of the CAFIU

**Article 5.-** Transaction Report Analysis Division shall receive Suspicious Transaction Reports (STRs) and other suspicious information for analysis and disseminate to

competent authorities. This division shall have two sections with the following functions:

1- Receive and Analysis Section

- Collect and receive STRs, Cash Transaction Reports (CTRs) and other information
- Receive electronic report from reporting entities
- Search for additional information and analyze STRs and CTRs
- Compile, maintain and process data in the information technology System
- Liaise with reporting entities

2- In and Out Feedback Section

- Prepare Suspicious and Financial Intelligent Reports
- Disseminate Intelligent report to competent authorities
- Send and receive feedback from competent authorities

**Article 6.-** Compliance Monitoring Division shall control and monitor the compliance of AML/CFT obligation of the reporting entities, train and raise awareness among the reporting entities and the public. This division shall have two sections with the following functions:

1- Compliance Monitoring Section

- Control and monitor the AML/CFT compliance of the reporting entities
- Prepare draft report and issue report format
- Identify all reporting entities in order to enforce their reporting obligations
- Strengthen the implementation of and compliance with policy and strategy
- Co-operate and coordinate with supervisory authorities of the reporting entities in order to control the AML/CFT compliance
- Provide recommendations to supervisory authorities of the reporting entities to strengthen its implementation and raise a request for sanction if necessary

2- Training and Awareness Raising Section

- Training and raise awareness on AML/CFT obligations
- Prepare planning and training program and awareness rising among reporting entities and the public
- Co-operate with other relevant divisions to present the actual case relating to money laundering and terrorist financing
- Co-operate and coordinate with supervisory authority of the reporting entities on training and awareness rising.

**Article 7.-** Co-operation Division shall cooperate and coordinate with domestic and international partner to detect and analyze actual case of money laundering and terrorism financing. This division shall have two sections with the following functions:

1- Domestic Co-operation Section

- Prepare domestic Memorandum of Understanding (MOU) with all relevant agencies
- Disseminate questionnaires relating to AML/CFT enforcement to all relevant agencies
- Provide opinions relating to AML/CFT enforcement
- Prepare meeting and solve any possible difficulty
- Collect and maintain actual case of domestic money laundering and terrorism financing for study and publication

2- International Co-operation Section

- Prepare report for the meeting of Asia Pacific Group on money laundering and other meetings
- Co-operate with international partners in AML/CFT
- Prepare MOU on the exchange of information and international cooperation
- Co-operate with international partners in preparing AML/CFT policy and strategy.
- Collect and maintain AML/CFT actual case for study and publication
- Prepare documents relating to membership of any international organizations in AML/CFT.

**Article 8.-** As otherwise mentioned above, each division shall perform any other functions set by the head of the CAFIU.

**Article 9.-** the General Secretariat, the General Direction, the General Cashier, the General Inspection and all departments under NBC's supervisory authority and the CAFIU shall strictly implement the present Prakas.

**Article 10.-** The present Prakas shall have effect from the signing date.

Phnom Penh, 16 September 2009
Governor and chairman of the CAFIU's BOD
Signed

**Chea Chanto**

Places:
- As article 9 for implementation
- Documentation

Copy:
- All members of CAFIU's BOD
- Council of the ministers for information
- Administrative department of the Council of the minister for publication in the national gazettes

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ: ១០២៥ ឧស្ស.ចសរ ឧក

រាជធានីភ្នំពេញ, ថ្ងៃទី២៧ខែ ធ្នូ ឆ្នាំ ២០១០

# ប្រកាស
# ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់នាយកដ្ឋានទឹកស្អាត

## រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការប្រកាសឲ្យប្រើច្បាប់បង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញ អនុក្រឹត្យ លេខ ៣៥ អនក្រ បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាលស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ពិនិត្យតាមសំណូមពរការងារចាំបាច់របស់ក្រសួង ។

## សម្រេច

**ប្រការ ១** : នាយកដ្ឋានទឹកស្អាតត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់របស់អគ្គនាយកដ្ឋានឧស្សាហកម្ម ។ នាយកដ្ឋានទឹកស្អាតត្រូវមានភារកិច្ចដូចតទៅ ៖
- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍ជាតិវិស័យទឹកស្អាត
- រៀបចំគម្រោងអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគសាធារណៈ ពាក់ព័ន្ធវិស័យទឹកស្អាត
- ប្រមូលព័ត៌មាន និងធ្វើបញ្ជីសារពើភ័ណ្ឌអង្គភាពរដ្ឋាករទឹកសាធារណៈ និងឯកជន
- គ្រប់គ្រង និងត្រួតពិនិត្យការធ្វើអាជីវកម្មទឹកស្អាតរបស់អង្គភាពរដ្ឋាករទឹកសាធារណៈ ក្នុងក្របខ័ណ្ឌនៃភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យនេះ
- ធ្វើបញ្ញត្តិកម្មលើវិស័យផ្គត់ផ្គង់ទឹកស្អាត ក្នុងក្របខណ្ឌជាបញ្ញត្តិករម្ចាស់វិស័យផ្គត់ផ្គង់ទឹកស្អាត

- រៀបចំប្រកាសអនុញ្ញាតឲ្យធ្វើអាជីវកម្មទឹកស្អាត និងត្រួតពិនិត្យតាមដានការអនុវត្តន៍ប្រកាសអនុញ្ញាត
- រៀបចំបទប្បញ្ញត្តិ បែបបទ នីតិវិធី បទបញ្ជា និងសេចក្តីណែនាំផ្សេងៗ ពាក់ព័ន្ធការផលិត ការផ្គត់ផ្គង់សេវា និងការប្រើប្រាស់ទឹកស្អាត
- រៀបចំស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេសនានា ពាក់ព័ន្ធវិស័យផ្គត់ផ្គង់ទឹកស្អាត
- រៀបចំស្តង់ដារគុណភាពទឹកផឹកជាតិ និងការត្រួតពិនិត្យគុណភាពទឹក
- រៀបចំ និងគ្រប់គ្រងកិច្ចសន្យាសម្បទាន និងឯកជនភាវូបនីយកម្មរដ្ឋាករទឹកសាធារណៈ
- ដឹកនាំអនុវត្ត សម្របសម្រួល និងទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធនានាក្នុងការជំរុញការគាំទ្រ និងការកសាងលើកកំពស់សមត្ថភាពនៅក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត
- សហប្រតិបត្តិការជាតិ និងអន្តរជាតិដើម្បីការអភិវឌ្ឍន៍វិស័យទឹកស្អាត ។

អាជីវកម្មក្នុងប្រកាសនេះ សំដៅការផលិត ការបញ្ជូន និងការចែកចាយទឹកស្អាត ព្រមទាំងការផ្តល់សេវាបន្ថែម ឬបន្ទាប់បន្សំផ្សេងៗទៀត ដែលភ្ជាប់ជាមួយសកម្មភាពទាំងនេះ ។

**ប្រការ ២** : នាយកដ្ឋានទឹកស្អាតដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

**ប្រការ ៣** : រចនាសម្ព័ន្ធរបស់នាយកដ្ឋានទឹកស្អាតត្រូវមានដូចតទៅ ៖

- ការិយាល័យរដ្ឋបាល
- ការិយាល័យគម្រោង
- ការិយាល័យផែនការ
- ការិយាល័យបញ្ញត្តិកម្ម
- ការិយាល័យបច្ចេកទេស

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

**ប្រការ ៤** : ការិយាល័យនីមួយៗ ចំណុះនាយកដ្ឋាន ត្រូវមានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

១. ការិយាល័យរដ្ឋបាល

*តួនាទី*

ការិយាល័យរដ្ឋបាល ជាសេនាធិការជំនួយការឲ្យថ្នាក់ដឹកនាំនាយកដ្ឋានលើការងាររដ្ឋបាល គ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស និងសរុប ។

*ភារកិច្ច*

- ការងារលិខិតស្នាម ចេញ-ចូល និងបញ្ជូនលិខិត
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ និងធ្វើបញ្ជីសារពើភ័ណ្ឌ
- គ្រប់គ្រងឯកសាររបស់នាយកដ្ឋាន និងការងារបណ្ណាល័យ
- សរុប និងធ្វើរបាយការណ៍អំពីការងារ និងសកម្មភាពផ្សេងៗ របស់នាយកដ្ឋាន

- លើកគម្រោងចំណាយរដ្ឋបាលប្រចាំឆ្នាំរបស់នាយកដ្ឋាន
- រៀបចំ អនុវត្ត និងគ្រប់គ្រងការងារអភិវឌ្ឍន៍ធនធានមនុស្សរបស់នាយកដ្ឋាន
- រៀបចំផែនការ និងអនុវត្តកម្មវិធីបណ្តុះបណ្តាលធនធានមនុស្សសំរាប់វិស័យផ្គត់ផ្គង់ទឹកស្អាត
- គ្រប់គ្រងវត្តមាន អវត្តមានមន្ត្រីរបស់នាយកដ្ឋាន
- រៀបចំទីកន្លែង ឯកសារ និងសម្របសម្រួលគ្រប់ការងារប្រជុំ ។

២. ការិយាល័យគម្រោង

*តួនាទី*

ការិយាល័យគម្រោង ជាសេនាធិការជំនួយការឲ្យថ្នាក់ដឹកនាំនាយកដ្ឋានលើការងារគម្រោងអភិវឌ្ឍន៍វិស័យផ្គត់ផ្គង់ទឹកស្អាត ។

*ភារកិច្ច*

- រៀបចំគម្រោង និងសហការសម្របសម្រួលអនុវត្តគម្រោង
- ពិនិត្យតាមដាន និងវាយតំលៃការអនុវត្តន៍គម្រោង
- រៀបចំ និងអនុវត្តការងារលទ្ធកម្ម
- រៀបចំកម្មវិធីវិនិយោគសាធារណៈ
- រៀបចំកិច្ចសន្យាសម្បទាន
- សម្របសម្រួល និងសហប្រតិបត្តិការការងារជាមួយអង្គការជាតិ អន្តរជាតិ និងស្ថាប័នពាក់ព័ន្ធ
- សម្របសម្រួលការងារជាមួយអ្នកពិគ្រោះយោបល់ជាតិ និងអន្តរជាតិ ។

៣. ការិយាល័យផែនការ

*តួនាទី*

ការិយាល័យផែនការ ជាសេនាធិការជំនួយការឲ្យថ្នាក់ដឹកនាំនាយកដ្ឋានលើការងារផែនការស្ថិតិ និងគោលនយោបាយ ។

*ភារកិច្ច*

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍ជាតិវិស័យទឹកស្អាត
- ពិនិត្យតាមដាន និងវាយតំលៃការអនុវត្តន៍គោលនយោបាយ យុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍វិស័យទឹកស្អាត និងធ្វើបច្ចុប្បន្នភាព
- សម្របសម្រួល និងរៀបចំផែនការសកម្មភាពវិស័យទឹកស្អាត
- ប្រមូលផ្តុំព័ត៌មាន រៀបចំស្ថិតិទឹកស្អាតតាមបណ្តារាជធានី-ខេត្ត
- ប្រមូលព័ត៌មាន និងធ្វើបញ្ជីសារពើភ័ណ្ឌធនធានទឹក
- ប្រមូលព័ត៌មាន និងធ្វើបញ្ជីសារពើភ័ណ្ឌអង្គភាពរដ្ឋាករទឹកសាធារណៈ
- គ្រប់គ្រង តាមដានការអនុវត្តន៍ និងវឌ្ឍនភាពរបស់អង្គភាពរដ្ឋាករទឹកសាធារណៈ
- ផ្តល់ការពិគ្រោះយោបល់លើផ្នែកគ្រប់គ្រង និងប្រតិបត្តិការ ការធ្វើអាជីវកម្មទឹកស្អាត

៤. ការិយាល័យបញ្ញត្តិកម្ម

*តួនាទី*

ការិយាល័យបញ្ញត្តិកម្ម ជាសេនាធិការជំនួយការឲ្យថ្នាក់ដឹកនាំនាយកដ្ឋានលើការងារបញ្ញត្តិកម្ម ។

*ភារកិច្ច*

- រៀបចំ និងអនុវត្តគោលនយោបាយថ្លៃទឹក
- ពិនិត្យ និងកំណត់ថ្លៃទឹក
- រៀបចំលិខិតបទដ្ឋានគតិយុត្តិ និងបទប្បញ្ញត្តិផ្សេងៗ សម្រាប់សម្របសម្រួល និងបញ្ញត្តិលើការធ្វើអាជីវកម្មទឹកស្អាត
- ត្រួតពិនិត្យការធ្វើអាជីវកម្មរបស់អង្គភាពរដ្ឋាករទឹកទាំងរដ្ឋ និងទាំងឯកជនក្នុងក្របខ័ណ្ឌការងារជាបញ្ញត្តិករ
- តាមដាន និងត្រួតពិនិត្យការអនុវត្តន៍កិច្ចសន្យាសម្បទាន
- រៀបចំចេញ កែសំរួល ព្យួរ ដកហូត ឬបដិសេធប្រកាសអនុញ្ញាតឲ្យធ្វើអាជីវកម្មទឹកស្អាត
- តាមដានការអនុវត្តន៍ប្រកាស និងបទបញ្ជារបស់ក្រសួង
- ដោះស្រាយវិវាទក្នុងការធ្វើអាជីវកម្ម និងការប្រើប្រាស់ទឹកស្អាត ។

៥. ការិយាល័យបច្ចេកទេស

*តួនាទី*

ការិយាល័យបច្ចេកទេស ជាសេនាធិការជំនួយការឲ្យថ្នាក់ដឹកនាំនាយកដ្ឋានលើការងាររៀបចំស្តង់ដារគុណភាពទឹក បទប្បញ្ញត្តិបច្ចេកទេស និងស្រាវជ្រាវ និងអភិវឌ្ឍន៍ (R&D) បច្ចេកទេសពាក់ព័ន្ធការផលិត និងផ្គត់ផ្គង់ទឹក ។

*ភារកិច្ច*

- រៀបចំស្តង់ដារគុណភាពទឹក និងធ្វើបច្ចុប្បន្នភាព
- តាមដាន និងត្រួតពិនិត្យគុណភាពទឹក
- លើកកំពស់ការយល់ដឹងរបស់ប្រជាជនអំពីទឹកស្អាត និងអនាម័យ
- រៀបចំស្តង់ដារ និងបទប្បញ្ញត្តិបច្ចេកទេសនានាពាក់ព័ន្ធការផលិត និងផ្គត់ផ្គង់ទឹកស្អាត
- រៀបចំ និងត្រួតពិនិត្យការអនុវត្តន៍ស្តង់ដារប្រតិបត្តិ
- កំណត់បែបបទការការពារបរិស្ថាន ការគ្រប់គ្រងសំណល់រឹង រាវ និងអនាម័យ
- ជំរុញការស្រាវជ្រាវ និងអភិវឌ្ឍន៍ (R&D) បច្ចេកទេសពាក់ព័ន្ធការផលិត និងផ្គត់ផ្គង់ទឹកស្អាត
- ផ្តល់ការពិគ្រោះយោបល់ផ្នែកបច្ចេកទេសលើការប្រតិបត្តិ និងថែរក្សាក្នុងដំណើរការផលិតកម្ម និងផ្គត់ផ្គង់ទឹកស្អាត ។

**ប្រការ ៥** : បទប្បញ្ញត្តិ និង សេចក្តីសម្រេចទាំងឡាយណា ដែលមានន័យផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦** : អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្ម អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានវិទ្យាស្ថាន នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក និងប្រធាននាយកដ្ឋានទឹកស្អាត មានភារកិច្ចអនុវត្តក្នុងក្របខ័ណ្ឌសមត្ថកិច្ចរៀងៗខ្លួនតាមប្រកាសនេះ ។

**ប្រការ ៧** : ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

**ស៊ុយ សែម**

**ចម្លងជូន:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- គ្រប់អគ្គនាយកដ្ឋាន វិទ្យាស្ថាន អគ្គាធិការដ្ឋាន
- គ្រប់នាយកដ្ឋានសេនាធិការ
- គ្រប់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានី-ខេត្ត "ដើម្បីជាពត៌មាន"
- ដូចប្រការ ៦ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធប្រកាសលេខ: ១០៤៦ ឧស.ប្រក
ចុះថ្ងៃទី២៧ ខែ ធ្នូ ឆ្នាំ ២០១០

## អង្គការលេខរបស់នាយកដ្ឋានទឹកស្អាត




បានឃើញ
រាជធានីភ្នំពេញ, ថ្ងៃទី២៧ខែ ធ្នូ ឆ្នាំ ២០១០
រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ស៊ុយ សែម

បានពិនិត្យត្រឹមត្រូវ
រាជធានីភ្នំពេញ, ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១០
អគ្គនាយកឧស្សាហកម្ម

ម៉េង សក្តិធារ៉ា

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១០
ប្រធាននាយកដ្ឋានទឹកស្អាត

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការពារជាតិ**
លេខ : ០៧៤/ប.ក/២០១០

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១០

# ប្រកាស
## ស្តីពី
## ការកំណត់ តួនាទី ភារកិច្ច ទីបញ្ជាការជួរមុខ និងបណ្តាការិយាល័យ របស់នាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាប្រធានគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៩/១២១១ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ ២០០៩ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសន្តិសុខ លម្ហសមុទ្រ
- បានឃើញអនុក្រឹត្យលេខ ៨៤.អនក្រ.បក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ
- តាមសំណើ របស់អគ្គលេខាធិការ នៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ

## សម្រេច

**ប្រការ១** : ទីបញ្ជាការជួរមុខរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ មានតួនាទីភារកិច្ច ដូចខាងក្រោម :

- ជាសេនាធិការប្រចាំការនៅមូលដ្ឋានរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.** ដើម្បីសម្របសម្រួលជាមួយបណ្តាជំនាញពាក់ព័ន្ធក្នុងការប្រើប្រាស់កំលាំង ធនធានផ្សេងៗ និងអនុវត្តតាមបទបញ្ជារបស់ **គ.ជ.ស.ស.** ក្នុងកិច្ចប្រតិបត្តិការ ។

- ស្រាវជ្រាវប្រមូលពត៌មាន ក្តាប់និងតាមដានជាប្រចាំរាល់សភាពការណ៍សន្តិសុខនៅក្នុងតំបន់ដែល **គ.ជ.ស.ស.** ទទួលខុសត្រូវ ។
- ធ្វើសកម្មភាពល្បាតតាមបទបញ្ជា របស់អគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.** រក្សាការពារសន្តិសុខសេដ្ឋកិច្ច ធនធានធម្មជាតិ បរិស្ថាននិងធ្វើអន្តរាគមន៍បានទាន់ពេលវេលា បង្ការ ទប់ស្កាត់ បង្ក្រាបបទល្មើសមាន ការគេចពន្ធ អន្តោប្រវេសន៍ ការជួញដូរអាវុធ គ្រឿងញៀន អំពើភេរវកម្ម ចោរកម្ម ការលួចចូលនេសាទខុសច្បាប់ នៅលើផ្ទៃសមុទ្រ នៃព្រះរាជាណាចក្រកម្ពុជា។
- ជាភ្នាក់ងារសម្របសម្រួលការអនុវត្តន៍ច្បាប់ដោយអនុវត្តតាមនីតិវិធី។
- ត្រួតពិនិត្យសុវត្ថិភាព និងសណ្តាប់ធ្នាប់ក្នុងការធ្វើអាជីវកម្មនៅតាមឆ្នេរ និងលើផ្ទៃសមុទ្រ ដែលបានកំណត់ដោយច្បាប់ របស់ព្រះរាជាណាចក្រកម្ពុជា។
- ប្រើប្រាស់កម្លាំងអន្តរាគមន៍ ធ្វើការស្រាវជ្រាវ រុករក និងសង្គ្រោះ នៅលើផ្ទៃសមុទ្រ ពេលមានគ្រោះមហន្តរាយដោយធម្មជាតិ ឧប្បទ្ទវហេតុធ្លាក់យន្តហោះ គ្រោះថ្នាក់នាវា- ទូកនេសាទ និង ធ្វើការដឹកជញ្ជូនមនុស្ស ជំលៀសពីតំបន់គ្រោះថ្នាក់។
- គ្រប់គ្រងត្រួតពិនិត្យរាល់សម្ភារៈ មធ្យោបាយ គ្រឿងបំពាក់ សម្រាប់ដំណើរការ បំពេញបេសកកម្មរបស់ទីបញ្ជាការជួរមុខ។
- រាយការណ៍ជាប្រចាំរាល់សភាពការណ៍ដែលកើតមាននៅក្នុងតំបន់ដែលទទួលខុសត្រូវ មកអគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.**។
- បូកសរុបរបាយការណ៍ខែ ត្រីមាស ឆមាស ៩ខែ និងឆ្នាំ ជូនអគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.**។
- ទទួលអនុវត្ត ភារកិច្ចផ្សេងទៀត ដែលអគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.** ប្រគល់ជូន។

**ប្រការ២** : ទីបញ្ជាការជួរមុខ ជាទីតាំងឈរជើងប្រចាំការ ។ បុគ្គលិកត្រូវបានជ្រើសតាំងសមាសភាពពីការិយាល័យ និងជំនួយការ នៃបណ្តានាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.** និងពីបណ្តាស្ថាប័ន កងឯកភាពពាក់ព័ន្ធដទៃទៀត ដើម្បីបំពេញបេសកម្ម ក្នុងកិច្ចប្រតិបត្តិការ និងសហប្រតិបត្តិការជាមួយបណ្តាជំនាញពាក់ព័ន្ធ នៅលើផ្ទៃសមុទ្រ និងឆ្នេរ ។

**ប្រការ៣** : ទីបញ្ជាការជួរមុខដឹកនាំដោយមេបញ្ជាការ ០១រូប និងមេបញ្ជាការរងមួយចំនួនជាជំនួយការទៅតាមតម្រូវការចាំបាច់ មានមួយកងនាវាអន្តរាគមន៍ និងផ្នែកចំនួន ០៦ ដូចខាងក្រោម :

- ផ្នែករដ្ឋបាល
- ផ្នែកប្រតិបត្តិការនិងបញ្ជូនសារ
- ផ្នែកសន្តិសុខ
- ផ្នែកបច្ចេកទេស
- ផ្នែកផ្គត់ផ្គង់
- ផ្នែកនីតិកម្ម

**ប្រការ៤** : តួនាទី ភារកិច្ច របស់បណ្តាការិយាល័យចំណុះនាយកដ្ឋានរដ្ឋបាល នាយកដ្ឋានផែនការ នាយកដ្ឋានគ្រប់គ្រងប្រតិបត្តិការ នាយកដ្ឋានផ្គត់ផ្គង់ និងនាយកដ្ឋាននីតិកម្ម មានដូចខាងក្រោម:

១ - **នាយកដ្ឋានរដ្ឋបាល** នៃអគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.** មានរចនាសម្ព័ន្ធ :

- លេខាធិការដ្ឋាន
- ការិយាល័យសរុប
- ការិយាល័យគ្រប់គ្រងបុគ្គលិក
- ការិយាល័យហ្វឹកហ្វឺន

និងមានតួនាទី ភារកិច្ច ដូចខាងក្រោម :

ក - <u>លេខាធិការដ្ឋាន</u>

- រៀបចំលិខិតអញ្ជើញផ្សេងៗ ទទួលនិងបញ្ជូនឯកសារ លិខិតស្នាមនានា ទៅស្ថាប័ន ក្រសួង និងកងឯកភាពដែលមានការពាក់ព័ន្ធ ។
- ទទួល និងធ្វើការត្រួតពិនិត្យរាល់ឯកសារ លិខិតស្នាម រៀបចំដាក់កំណត់បង្ហាញរាយការណ៍តាមឋានានុក្រម សុំសេចក្តីសំរេចពីថ្នាក់លើ ។ ធ្វើការបោះពុម្ពផ្សព្វផ្សាយនូវរាល់ឯកសារ លិខិតស្នាម លិខិតបទដ្ឋានទាំងឡាយ របស់ក្រសួង និងស្ថាប័ននានា ដែលបានសំរេចប្រកាសប្រើជាសាធារណៈ។
- បូកសរុបរបាយការណ៍ ថែរក្សារាល់ទ្រព្យសម្បត្តិ ចលនទ្រព្យ និងអចលនទ្រព្យ រៀបចំចងក្រងតំកល់ឯកសារ និងលិខិតស្នាមនានាឲ្យមានរបៀបរៀបរយ គ្រប់គ្រង និងប្រើប្រាស់ត្រាសិទ្ធិគណៈកម្មាធិការជាតិសន្តិសុខ លម្ហសមុទ្រ ។
- ទទួលអនុវត្ត ភារកិច្ចផ្សេងទៀត ដែលនាយកដ្ឋានរដ្ឋបាល ប្រគល់ជូន ។

ខ - <u>ការិយាល័យសរុប</u>

- បូកសរុបរបាយការណ៍ ខែ ត្រីមាស ឆមាស ៩ខែ ឆ្នាំ និង ធ្វើកំណត់ហេតុរាល់ការប្រជុំរបស់អគ្គលេខាធិការដ្ឋាន និងរបស់គណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ ។
- ធ្វើការពិនិត្យរៀបចំទីកន្លែងប្រជុំ និងក្នុងពិធីផ្សេងៗ របស់អគ្គលេខាធិការដ្ឋាន ធ្វើបដិសណ្ឋារកិច្ចជូនចំពោះភ្ញៀវ ដែលបានអញ្ជើញចូលរួម និងពិធីការជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន។
- ទទួលអនុវត្ត ភារកិច្ចផ្សេងទៀត ដែលនាយកដ្ឋានរដ្ឋបាល ប្រគល់ជូន ។

គ - <u>ការិយាល័យគ្រប់គ្រងបុគ្គលិក</u>

- គ្រប់គ្រងនាយទាហាន នាយនគរបាល និងមន្ត្រីរាជការដែលមានចំពោះមុខ និងទៅអនាគត ដែលបម្រើការងារក្នុងរង្វង់ក្របខ័ណ្ឌ អគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.**។
- រៀបចំបំពេញបែបបទទាំងឡាយ ដែលពាក់ព័ន្ធដល់ការតម្លើងឋានន្តរស័ក្តិ ការតែងតាំងផ្លាស់ប្តូរមុខងារ លើកសរសើរ គ្រឿងឥស្សរិយស សោធននិវត្តន៍ គោលនយោបាយ ប្រវត្តិរូប អត្តសញ្ញាណប័ណ្ណ និងឯកសារផ្សេងៗទៀត ។
- ធ្វើការត្រួតពិនិត្យ និងជ្រើសរើសកំលាំងក្នុងក្របខ័ណ្ឌអគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.**និងកម្លាំងជំនាញពាក់ព័ន្ធ រៀបចំបញ្ជូនទៅបណ្តុះបណ្តាល បំប៉ន តាមផែនការរបស់ថ្នាក់លើ ។
- ទទួលអនុវត្ត ភារកិច្ចផ្សេងទៀត ដែលនាយកដ្ឋានរដ្ឋបាល ប្រគល់ជូន ។

ឃ- <u>ការិយាល័យហ្វឹកហ្វឺន</u>

- រៀបចំផែនការ និងសហការជាមួយជំនាញពាក់ព័ន្ធ សំរាប់ការហ្វឹកហ្វឺនបណ្តុះបណ្តាល បំប៉ន នាយទាហាន នាយនគរបាល និងមន្ត្រីរាជការ តាមផែនការរបស់ថ្នាក់លើ។
- រៀបចំស្រាវជ្រាវ និង ចងក្រងរាល់ឯកសារពាក់ព័ន្ធការងារប្រតិបត្តិការ និងសហប្រតិបត្តិការ

នៅតាមតំបន់ឆ្នេរ និងលើផ្ទៃសមុទ្រ ។

- អនុវត្តកម្មវិធីហ្វឹកហ្វឺន រយៈពេលខ្លី មធ្យម វែង ជាប្រចាំដល់នាវិក និងមន្ត្រីរបស់ **គ.ជ.ស.ស.** ។
- ទទួលអនុវត្ត ភារកិច្ចផ្សេងទៀត ដែលនាយកដ្ឋានរដ្ឋបាល ប្រគល់ជូន។

២ - **នាយកដ្ឋានផែនការ** នៃអគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.** មានរចនាសម្ព័ន្ធ :

- ការិយាល័យផែនការ
- ការិយាល័យស្រាវជ្រាវយុទ្ធសាស្ត្រ
- ការិយាល័យសហប្រតិបត្តិការអន្តរជាតិ

និងមានតួនាទី ភារកិច្ច ដូចខាងក្រោម :

ក - <u>ការិយាល័យផែនការ</u>

- មានភារកិច្ចរៀបចំអភិវឌ្ឍគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាព រយៈពេល ខ្លី មធ្យម វែង ដើម្បីបង្ការ ទប់ស្កាត់ ការពារ និងធ្វើអន្តរាគមន៍ប្រកបដោយប្រសិទ្ធិភាព និងទាន់ពេលវេលាចំពោះការរំលោភបំពាន និងបទល្មើសទាំងឡាយព្រមទាំងត្រៀមលក្ខណៈ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការសង្គ្រោះគ្រោះមហន្តរាយ និងការការពារបរិស្ថាន។
- រៀបចំផែនការជាក់លាក់របស់ **គ.ជ.ស.ស** អំពីការគ្រប់គ្រងការចាត់ចែង ការសម្របសម្រួល និងការទទួលខុសត្រូវលើកម្លាំងសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ ។
- ទទួលអនុវត្តភារកិច្ចផ្សេងៗ ទៀត ដែលប្រធាននាយកដ្ឋានផែនការប្រគល់ជូន។

ខ - <u>ការិយាល័យស្រាវជ្រាវយុទ្ធសាស្ត្រ</u>

- មានភារកិច្ចសិក្សាស្រាវជ្រាវ និងលើកស្ទួយការយល់ដឹងអំពីសន្តិសុខសម្តសមុទ្រ ។
- ធ្វើបច្ចុប្បន្នភាព លើសភាពការណ៍សន្តិសុខលម្អសមុទ្រ និងតំបន់ជាប់មាត់សមុទ្រ។
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនអគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.**
- ទទួលអនុវត្តភារកិច្ចផ្សេងៗ ទៀត ដែលប្រធាននាយកដ្ឋានផែនការប្រគល់ជូន។

គ - <u>ការិយាល័យសហប្រតិបត្តិការអន្តរជាតិ</u>

- ជាចំណុចកណ្តាល នៅក្នុងការធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន បណ្តាប្រទេសដៃគូសន្តិសុខ អង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិនានា ដើម្បីស្វែងរកការឧបត្ថម្ភគាំទ្រ សម្រាប់ការអភិវឌ្ឍន៍សមត្ថភាព កម្លាំង និងសម្ភារៈផ្សេងៗ ។
- ទទួលអនុវត្តភារកិច្ចផ្សេងៗ ទៀត ដែលប្រធាននាយកដ្ឋានផែនការប្រគល់ជូន។

៣ - **នាយកដ្ឋានគ្រប់គ្រងប្រតិបត្តិការ** នៃអគ្គលេខាធិការដ្ឋាន មានរចនាសម្ព័ន្ធ :

- ការិយាល័យគ្រប់គ្រងសភាពការណ៍
- ការិយាល័យអន្តរាគមន៍
- ការិយាល័យពត៌មានចារកម្ម
- ការិយាល័យបញ្ជូនសារ

និងមានតួនាទី ភារកិច្ច ដូចខាងក្រោម

ក - <u>ការិយាល័យគ្រប់គ្រងសភាពការណ៍</u>

- ក្តាប់ និងតាមដានជាប្រចាំ រាល់សភាពការណ៍ដែលកើតមាននៅក្នុងតំបន់ដែល **គ.ជ.ស.ស** ទទួលខុសត្រូវរួចរាយការណ៍ជូន អគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.** ។

- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលប្រធាននាយកដ្ឋានគ្រប់គ្រងប្រតិបត្តិការប្រគល់ជូន។

ខ - ការិយាល័យអន្តរាគមន៍

- អនុវត្តវិធានការសម្របសម្រួល នៃការប្រើប្រាស់កម្លាំង សម្ភារៈ និងធនធានផ្សេងៗសម្រាប់កិច្ចប្រតិបត្តិការទាំងឡាយរបស់**គ.ជ.ស.ស**នៅក្នុងបេសកកម្មការពារសន្តិសុខនិងអនុវត្តច្បាប់។
- ធ្វើបទបញ្ជាប្រតិបត្តិការសំរាប់បេសកកម្មនិមួយៗ(សហការ ,បង្ក្រាប , សង្គ្រោះ , រុករក......)
- គ្រប់គ្រងកិច្ចប្រតិបត្តិការ និងការបំពេញបេសកកម្មរបស់កំលាំងសមត្ថកិច្ច **គ.ជ.ស.ស.** ។
- ធ្វើការបូកសរុបវាយតម្លៃអំពីលទ្ធផលនៃកិច្ចប្រតិបត្តិការការពារសន្តិសុខ និងការអនុវត្តន៍ច្បាប់។
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានគ្រប់គ្រងប្រតិបត្តិការប្រគល់ជូន។

គ - ការិយាល័យព័ត៌មាន ចារកម្ម

- គ្រប់គ្រង និងអនុវត្តការងារព័ត៌មានចារកម្ម ។
- ប្រមូលពត៌មានពីគ្រប់មជ្ឈដ្ឋាន ពីកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសជាដៃគូក្នុងតំបន់ និងអន្តរជាតិ ព្រមទាំងតាមរយៈប្រព័ន្ធព័ត៌មានវិទ្យា។
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនអគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.**។
- ទទួលអនុវត្តភារកិច្ចផ្សេងៗ ទៀត ដែលប្រធាននាយកដ្ឋានគ្រប់គ្រងប្រតិបត្តិការប្រគល់ជូន។

ឃ- ការិយាល័យបញ្ជូនសារ

- ធានាបញ្ជូនសារការប្រកាសចូលសភាពត្រៀមលក្ខណៈប្រតិបត្តិការ ដល់បណ្តាអង្គភាពក្នុងតំបន់ **គ.ជ.ស.ស.**ទទួលខុសត្រូវ។
- ធានាបញ្ជូនសារ ជូនដំណឹងប្រកាសអាសន្ន អំពីសភាពការណ៍លើតំបន់ឆ្នេរ និងលម្ហសមុទ្រក្នុងតំបន់ **គ.ជ.ស.ស.**។
- ធានាបញ្ជូនសារការងារបញ្ជា របស់ **គ.ជ.ស.ស.**។
- ធានាបញ្ជូនសារឲ្យការងារសហការ បង្ក្រាប សង្គ្រោះ រុករក លើនិងក្នុងលម្ហសមុទ្រ ទាំងក្នុងតំបន់ និងអន្តរជាតិ ។
- ធានាបញ្ជូនសារឲ្យការងារបញ្ជាដឹកនាំ លើផ្នែកការងារភស្តុភារ បច្ចេកទេសរបស់**គ.ជ.ស.ស**។
- ទទួលអនុវត្តភារកិច្ចផ្សេងៗ ទៀត ដែលប្រធាននាយកដ្ឋានគ្រប់គ្រងប្រតិបត្តិការប្រគល់ជូន។

**៤ - នាយកដ្ឋានផ្គត់ផ្គង់** នៃអគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.** មានរចនាសម្ព័ន្ធ :

- ការិយាល័យភស្តុភារ
- ការិយាល័យគ្រប់គ្រងថវិកា
- ការិយាល័យបច្ចេកទេស
- ការិយាល័យលទ្ធកម្ម

និងមានតួនាទី ភារកិច្ច ដូចខាងក្រោម

ក - ការិយាល័យភស្តុភារ

- គ្រប់គ្រង និងផ្គត់ផ្គង់ប្រេងឥន្ធនៈ ទ្រព្យសម្ភារៈ និងឧបករណ៍បរិក្ខារផ្សេងៗ សម្រាប់ទ្រទ្រង់កិច្ចប្រតិបត្តិការ និងការបំពេញបេសកកម្មនានា ដល់គ្រប់នាយកដ្ឋានក្រោមចំណុះ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ ។
- កត់ត្រាតាមដានរាល់ការងារបញ្ចូលបញ្ចេញស្តុកប្រេងឥន្ធនៈ ទ្រព្យសម្ភារៈ និងឧបករណ៍ បរិក្ខារ

ផ្សេងៗប្រចាំថ្ងៃ ខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូននាយកដ្ឋាន តាមនីតិវិធីហិរញ្ញវត្ថុ។

- ចូលរួមត្រួតពិនិត្យដោយសហការជាមួយការិយាល័យបច្ចេកទេសរាល់ការជួសជុល ឧបករណ៍ យានយន្ត អគារ និងសម្ភារៈប្រើប្រាស់ផ្សេងៗដែលជាមធ្យោបាយសម្រាប់ ដំណើរការ និងការបំពេញបេសកកម្ម របស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិសន្តិសុខ លម្ហសមុទ្រ ។
- ទទួលភារកិច្ចតាមការចាត់តាំងរបស់ប្រធាននាយកដ្ឋាន ។

ខ - <u>ការិយាល័យគ្រប់គ្រងថវិកា</u>

- គ្រប់គ្រង ត្រួតពិនិត្យនិងទូទាត់ចំណាយប្រេងឥន្ធនៈ ទ្រព្យសម្ភារៈ និងឧបករណ៍បរិក្ខារផ្សេងៗ ដែលទិញសម្រាប់ប្រើប្រាស់ទ្រទ្រង់កិច្ចប្រតិបត្តិការនិងការបំពេញបេសកកម្មនានា ដល់គ្រប់នាយកដ្ឋានក្រោមចំណុះ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ ។
- គ្រប់គ្រង ត្រួតពិនិត្យ និងទូទាត់ចំណាយរាល់ការជួសជុល ឧបករណ៍, យានយន្ត, អគារ និងសម្ភារៈប្រើប្រាស់ផ្សេងៗ ដែលជាមធ្យោបាយសម្រាប់ដំណើរការ និងការបំពេញបេសកកម្មរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ ។
- ទទួលបន្ទុកត្រួតពិនិត្យ និងទូទាត់ឲ្យទាន់ពេលវេលា រាល់ចំណាយផ្សេងៗ ប្រចាំថ្ងៃ របស់នាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.** ។
- កត់ត្រា តាមដានទូរាល់ប្រភពចំណូលដែលផ្តល់សំរាប់ដំណើការ និងការបំពេញបេសកកម្មរបស់អគ្គលេខាធិការដ្ឋាន ។
- គ្រប់គ្រងកត់ត្រាតាមដានថវិកាចំណូល ចំណាយប្រចាំថ្ងៃរបស់អគ្គលេខាធិការដ្ឋាន ។
- ធ្វើរបាយការណ៍ហិរញ្ញវត្ថុ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនប្រធាននាយកដ្ឋាន ។
- រៀបចំផែនការចំណាយថវិកា ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ របស់នាយកដ្ឋាន។
- ទទួលភារកិច្ចតាមការចាត់តាំងរបស់ប្រធាននាយកដ្ឋាន ។

គ - <u>ការិយាល័យបច្ចេកទេស</u>

- ផ្សព្វផ្សាយ ណែនាំការអនុវត្តច្បាប់ អនុក្រឹត្យ សារាចរ និង លិខិតបទដ្ឋានផ្សេងៗ ពាក់ព័ន្ធការងារផ្គត់ផ្គង់ និងការចំណាយទៅតាមនីតិវិធីហិរញ្ញវត្ថុ ។
- រៀបចំផែនការចំណូល-ចំណាយថវិកាប្រចាំត្រីមាស ឆមាសនិងប្រចាំឆ្នាំ របស់អគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.** ដោយសហការជាមួយគ្រប់នាយកដ្ឋានរបស់អគ្គលេខាធិការដ្ឋាន នៃ **គ.ជ.ស.ស.**។
- ចូលរួមត្រួតពិនិត្យលក្ខណៈបច្ចេកទេសលើការទិញ ជួសជុល និងការធ្វើលទ្ធកម្ម ប្រេងឥន្ធនៈ ទ្រព្យសម្ភារៈមធ្យោបាយ និងឧបករណ៍បរិក្ខារផ្សេងៗ ដែលសម្រាប់ប្រើប្រាស់ ទ្រទ្រង់កិច្ចប្រតិបត្តិការ និងការបំពេញបេសកកម្មនានាដល់គ្រប់នាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.**។
- គ្រប់គ្រងត្រួតពិនិត្យធ្វើបញ្ជីសារពើភណ្ឌ ទ្រព្យសម្បត្តិ សម្ភារៈ មធ្យោបាយនិងឧបករណ៍ផ្សេងៗប្រចាំឆ្នាំ របស់អគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.** ។
- ទទួលភារកិច្ចតាមការចាត់តាំងរបស់ប្រធាននាយកដ្ឋាន ។

ឃ- <u>ការិយាល័យលទ្ធកម្ម</u>

- រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ របស់អគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស** ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ ។

- គ្រប់គ្រងរៀបចំអនុវត្តការងារលទ្ធកម្មតាមវិធីសាស្ត្រលទ្ធកម្មសាធារណៈជាធរមាន ។
- រៀបចំរបាយការណ៍លទ្ធកម្មសាធារណៈរបស់អគ្គលេខាធិការ **គ.ជ.ស.ស.** ។
- រៀបចំឯកសារប្រគល់-ទទួលនូវរាល់ទ្រព្យសម្បត្តិ សម្ភារៈ មធ្យោបាយ និងឧបករណ៍បរិក្ខារផ្សេងៗដល់នាយកដ្ឋាននានា ចំណុះអគ្គលេខាធិការ **គ.ជ.ស.ស.** ។
- ទទួលភារកិច្ចតាមការចាត់តាំងរបស់ប្រធាននាយកដ្ឋាន ។

**៥- នាយកដ្ឋាននីតិកម្ម** នៃអគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.** មានរចនាសម្ព័ន្ធ :

- ការិយាល័យស្រាវជ្រាវច្បាប់
- ការិយាល័យសម្របសម្រួលផ្នែកច្បាប់
- ការិយាល័យទំនាក់ទំនងសាធារណៈ

និងមានតួនាទី ភារកិច្ច ដូចខាងក្រោម :

ក - <u>ការិយាល័យស្រាវជ្រាវច្បាប់</u>

- ធ្វើការសិក្សាស្រាវជ្រាវ អំពីច្បាប់ជាតិ និងអន្តរជាតិ ដែលពាក់ព័ន្ធសន្តិសុខលម្ហសមុទ្រ បទល្មើសបរិស្ថានលើផ្ទៃសមុទ្រ និងឆ្នេរ... ។ល។
- រៀបចំសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិទាំងឡាយណាដែលត្រូវការចាំបាច់នៅក្នុងវិស័យសន្តិសុខលម្ហសមុទ្រ ដើម្បីឲ្យច្បាប់របស់ប្រទេសជាតិ ឆ្លុះបញ្ចាំងជាមួយច្បាប់អន្តរជាតិ ។
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងឆ្នាំ។
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលប្រធាននាយកដ្ឋាននីតិកម្មប្រគល់ជូន។

ខ - <u>ការិយាល័យសម្របសម្រួលផ្នែកច្បាប់</u>

- ធ្វើការងារផ្នែកច្បាប់ក្នុងករណីបទល្មើសសន្តិសុខលម្ហសមុទ្រ និងក្នុងនាម **គ.ជ.ស.ស.**នៅក្នុងការដោះស្រាយបញ្ហាដែលពាក់ព័ន្ធ និងផ្នែកច្បាប់។
- ធ្វើការពិនិត្យ និងចងក្រងឯកសារដែលពាក់ព័ន្ធស្តីពីការវិវាទ និងការអភិវឌ្ឍន៍របស់ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗក្នុងវិស័យសន្តិសុខលម្ហសមុទ្ររបស់ជាតិ ក្នុងតំបន់ អន្តរជាតិ និងធ្វើបច្ចុប្បន្នភាពរៀងរាល់ត្រីមាស និងឆមាស ។
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលប្រធាននាយកដ្ឋាននីតិកម្មប្រគល់ជូន។

គ - <u>ការិយាល័យទំនាក់ទំនងសាធារណៈ</u>

- ធ្វើការអប់រំ និងបញ្ជ្រាបការយល់ដឹងផ្នែកច្បាប់ និងបទប្បញ្ញត្តិនានា ដល់កងកម្លាំងសមត្ថកិច្ចពាក់ព័ន្ធព្រមទាំងចូលរួមចំណែកក្នុងការពង្រីកការយល់ដឹងនេះ នៅក្នុងសហគមន៍ប្រជាពលរដ្ឋ។
- រៀបចំធ្វើផែនការ និងសកម្មភាព រយៈពេលខ្លី មធ្យម វែង និងគ្រប់គ្រងមន្ត្រី បុគ្គលិក និងកញ្ចប់ថវិការបស់នាយកដ្ឋាន។
- ទទួល និងគ្រប់គ្រងរាល់ឯកសារ លិខិតស្នាមផ្សេងៗរបស់នាយកដ្ឋាន និងធ្វើរបាយការណ៍បូកសរុបប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនអគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.**។
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលប្រធាននាយកដ្ឋាននីតិកម្មប្រគល់ជូន។

**ប្រការ៩** : - ការិយាល័យនីមួយៗ របស់បណ្តានាយកដ្ឋាន ចំណុះអគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.** ត្រូវដឹកនាំដោយប្រធានមួយរូបនិងអមដោយអនុប្រធានមួយចំនួនជាជំនួយការ ទៅតាមតម្រូវការចាំបាច់។

**ប្រការ៦** : អគ្គលេខាធិការ ក្រសួងការពារជាតិ អគ្គលេខាធិការនៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ បណ្តាក្រសួង ស្ថាប័ន កងឯកភាពដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តតាមប្រកាសនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ**
**និងជាប្រធានគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ**

**នាយឧត្តមសេនីយ៍.ទៀ-បាញ់**

**ផ្ញើជូន**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ដូចប្រការ៦
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១១៧០ ពណ.ចបព

ភ្នំពេញថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១០

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : ហ្វាងឆឹង រៀល អ៊ីស្តេត អ៊ិនវេសមេន
FANGCHENG REAL ESTATE INVESTMENT Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ០៤២៧KH/២០១០ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១០

មានទម្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក ហ្វូ សានលីន ប្រធានក្រុមប្រឹក្សាភិបាល
លោក YU SHILIN អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៣៧ ផ្លូវលេខ ៩៥ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ - នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងទូរផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម - ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-វិនិយោគ និងអភិវឌ្ឍន៍អចលនទ្រព្យ

-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកាំរៃជើងសាលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/.

ទេសរដ្ឋមន្ត្រី

ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

អនុរដ្ឋលេខាធិការ

ហ៊ូ-សារ៉ាន់

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល -ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន -ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងបរិស្ថាន
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ស.ស.រ - ឯកសារ -កាលប្បវត្តិ